ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ដំណាំស្ពៃតឿក្នុងផ្ទះសំណាញ់
# PAK CHOY IN NET HOUSE



រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**

ខែឧសភា ឆ្នាំ២០២៣

## មាតិកា


**១-សេចក្តីផ្តើម** .......... ១

**២-គោលបំណង** .......... ១

**៣-បច្ចេកទេសដាំដុះ** .......... ១

៣.១ ការសាងសង់ផ្ទះសំណាញ់ .......... ១

៣.២ ការជ្រើសរើសពូជ .......... ១

៣.៣ ការបណ្តុះកូនដំណាំ .......... ២

៣.៤ ការដាំដុះ .......... ២

៣.៥ ការថែទាំ .......... ២

៣.៦ ការដាក់ជី .......... ២

៣.៧ កត្តាចង្រៃ .......... ២

៣.៨ ការប្រមូលផល .......... ៣

៣.៩ និន្នាកាតម្លៃ .......... ៣

**៤-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំ "ស្ពៃតឿ" ក្នុងផ្ទះសំណាញ់ទំហំ ២៥0 ម៉$^២$** .......... ៣

**៥-ការវិភាគសេដ្ឋកិច្ចលើការដាំ "ស្ពៃតឿ" ក្នុងផ្ទះសំណាញ់ទំហំ ២៥0 ម៉$^២$** .......... ៣

**៦-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ ស្ពៃតឿ ក្នុងផ្ទះសំណាញ់ទំហំ ២៥0 ម៉$^២$** .......... ៤

**៧-ខ្សែច្រវ៉ាក់តម្លៃ** .......... ៥

**៨-ការដាំដុះលក្ខណៈ: វិលជុំ** .......... ៥

**៩-ហានិភ័យ** .......... ៦

**១០-សេចក្តីសន្និដ្ឋាន** .......... ៧

# ដំណាំស្ពៃតឿក្នុងផ្ទះសំណាញ់

## ១-សេចក្តីផ្តើម

ស្ពៃតឿជាបន្លែស្លឹកដែលមានរូបរាងខ្លី មានធាងក្រាស់។ នៅលើទីផ្សារប្រទេសកម្ពុជាមានស្ពៃតឿ ៣ប្រភេទ÷ ១)- ស្ពៃតឿគល់ពណ៌ស ស្លឹកបៃតង ២)-ស្ពៃតឿគល់ពណ៌បៃតង ស្លឹកបៃតង និង៣)-គល់ពណ៌បៃតង ស្លឹកពណ៌ស្វាយ ក៏ប៉ុន្តែស្ពៃតឿគល់ពណ៌បៃតង ស្លឹកបៃតង គឺមានតម្រូវការទីផ្សារច្រើនជាងស្ពៃតឿពីរប្រភេទផ្សេងទៀត។ ស្ពៃតឿជាបន្លែស្លឹកដែលពេញនិយមសម្រាប់មុខម្ហូបដែលមានរសជាតិឈ្ងុយឆ្ងាញ់។ ស្ពៃតឿជាបន្លែដែលមានអាយុកាលដាំដុះខ្លី ឆាប់បានប្រមូលផល និងមិនប្រកាន់រដូវកាលដាំដុះឡើយ។

## ២-គោលបំណង

១. បង្ហាញអំពីបច្ចេកទេសដាំដុះ ថ្លៃដើមផលិត និន្នាកាតម្លៃ ការវិភាគសេដ្ឋកិច្ច និងបញ្ហាប្រឈមផ្សេងៗ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការផលិតឱ្យទទួលបានលទ្ធផលល្អ។

២. បំពេញបន្ថែមនូវកង្វះខាតមួយចំនួនក្នុងដំណើរការដាំដុះបន្លែស្ពៃតឿ។

## ៣-បច្ចេកទេសដាំដុះបន្លែស្ពៃតឿ

**៣.១ ការសាងសង់ផ្ទះសំណាញ់÷** ទំហំផ្ទះសំណាញ់ជាទូទៅប្រែប្រួលទៅតាមសណ្ឋានដី បរិមាណបន្លែដែលត្រូវផ្គត់ផ្គង់មកទីផ្សារ ដោយរួមបញ្ចូលការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណក់ទឹក។

**៣.២ ការជ្រើសរើសពូជ÷**គ្រាប់ពូជស្ពៃតឿត្រូវបានផលិត និងនាំចូលមកលក់ក្នុងទីផ្សារប្រទេសកម្ពុជាតាមរយៈក្រុមហ៊ុនជាច្រើន។ ខាងក្រោមនេះគឺជាគ្រាប់ពូជស្ពៃតឿគល់បៃតង ស្លឹកបៃតង មួយចំនួនដែលមានលក់តាមទីផ្សារ។









**៣.៣ ការបណ្ដុះកូនដំណាំ÷** សម្ភារៈសម្រាប់បណ្ដុះកូនស្ពៃតឿរួមមាន ថាសបណ្ដុះ ដីបណ្ដុះ ធុងបាញ់ទឹក និងគ្រាប់ពូជ។ កសិករត្រូវយកដីបណ្ដុះដាក់ចូលក្នុងថាសបណ្ដុះ និងដាក់គ្រាប់ពូជ ពី១គ្រាប់ ទៅ ២គ្រាប់ក្នុងមួយរណ្ដៅ បន្ទាប់មកត្រូវរោយដីបណ្ដុះពីលើគ្រាប់ស្តើងៗ និងស្រោចទឹកដោយប្រើប្រាស់ធុងបាញ់ទឹក។ ត្រូវយកថាសបណ្ដុះទៅដាក់ក្នុងរោងបណ្ដុះ ទុកឱ្យកូនដំណាំដុះលូតលាស់បាន ២ សប្ដាហ៍។

**៣.៤ ការដាំដុះ÷** ក្រោយបណ្ដុះកូនដំណាំបាន ២ សប្ដាហ៍រួចមក កសិករត្រូវជ្រើសរើសកូនស្ពៃធំៗ និងកូនស្ពៃតូចៗដាំក្នុងរងដាច់ដោយឡែកពីគ្នា ដើម្បីកូនដំណាំអាចលូតលាស់បានស្មើគ្នា មិនប្រជែងការទទួលពន្លឺ ទឹក និងការស្រូបយកជីជាតិ។ ស្ពៃតឿអាចដាំចន្លោះគុម្ព ១៥-២០ ស.ម ដាក់ដាំពី ៤-៥ ជួរក្នុងមួយរងដំណាំដែលមានទទឹង ១ម៉ែត្រ។

**៣.៥ ការថែទាំ÷** ត្រូវស្រោចទឹកក្នុងមួយថ្ងៃ ២ដង គឺនៅពេលព្រឹក និងពេលរសៀល ដោយផ្អែកលើសំណើមដី។ ប៉ុន្តែពេលរសៀលចាប់ពីម៉ោង ៥ ឡើងទៅមិនគួរស្រោចស្រពទឹកនោះទេ ព្រោះអាចបង្កឱ្យកើតជំងឺផ្សិតលើដំណាំស្ពៃ។

**៣.៦ ការដាក់ជី÷** តាមការបញ្ជាក់ពីកសិករ ដោយសារស្ពៃតឿមានអាយុកាលដាំដុះខ្លី ដូច្នេះការប្រើប្រាស់ជីធម្មជាតិប្រភេទ៤-៣-៣ សារធាតុសរីរាង្គ៦៥% ត្រូវបានប្រើប្រាស់តែម្ដងគត់នៅពេលរៀបចំដីមុនដាំកូនស្ពៃ។

**៣.៧ កត្តាចង្រៃ÷**









**៣.៨ ការប្រមូលផល៖** ស្ពៃតឿ ក្រោយពេលដាំដុះក្នុងផ្ទះសំណាញ់អាយុពី ២២ ទៅ ២៨ ថ្ងៃ គឺអាចប្រមូលផលបាន។ ដោយស្ពៃតឿមានអាយុកាលខ្លី ដូច្នេះអាចធ្វើការដាំដុះពី ៨ ទៅ ១០ វគ្គក្នុងមួយឆ្នាំ ប៉ុន្តែគប្បីដាំដំណាំបង្វិល ដើម្បីកាត់បន្ថយសត្វល្អិតចង្រៃ ជំងឺ និងខ្សោះជីជាតិរបស់ដី។ មុនពេលប្រមូលផលស្ពៃតឿ កសិករមិនគួរស្រោចស្រពទឹកនោះទេ ព្រោះធ្វើឱ្យដើមស្ពៃស្រួយ និងងាយរលួយ។

**៣.៩ និន្នាកាតម្លៃ៖** ស្ពៃតឿមានតម្លៃខ្ពស់នៅរដូវវស្សា ដោយសារផ្ទៃដីភាគច្រើនរបស់កសិករដាំដុះដំណាំស្រូវ មានភ្លៀងធ្លាក់ជោគជាំ និងលិចទឹកមិនអាចដាំបាន។ តម្លៃធ្លាក់ចុះក្នុងចន្លោះពីខែធ្នូដល់ខែមេសា ជារដូវទឹកសម្រកអាចដាំបានច្រើន ជារដូវងាយស្រួលដាំដុះ។

## ៤-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំ “ស្ពៃតឿ ”ក្នុងផ្ទះសំណាញ់ទំហំ ២៥0 ម៉ែ$^{២}$

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---:|
| ចំណាយលើការដាំដុះ | 322,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 3,800,000 |
| ផ្ទះសំណាញ់ និងសម្ភារៈផ្សេងៗ | 16,580,000 |
| **សរុប** | **20,702,000** |

**៥-ការវិភាគសេដ្ឋកិច្ចលើការដាំ ស្ពៃតឿ ក្នុងផ្ទះសំណាញ់ទំហំ ២៥0 ម៉ែ$^{២}$ (អាចដាំ ៨វគ្គ/ឆ្នាំ) រយៈពេលពីដាក់គ្រាប់រហូតប្រមូលផល ៣៥ ថ្ងៃ** (ការដាំដុះនៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល)

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ (៛) ១ឯកត្តា | ទឹកប្រាក់សរុប (៛) | ចំនួនសាររំលស់ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|
| **១-ចំណូលសរុបពីការលក់ស្ពៃតឿ** | | | | | | **1,400,000** |
| ចំណូលពីការលក់ | គ.ក | 400 | 3,500 | 1,400,000 | | 1,400,000 |
| **២-ចំណាយសរុប** = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ | | | | | | **832,000** |
| ២.ក. ចំណាយប្រែប្រួល | | | | | | 322,000 |
| ពូជ | កញ្ចប់ | 6 | 3,000 | 18,000 | | 18,000 |
| ជីលាមកសត្វ | ការ៉ុង | 1 | 50,000 | 50,000 | | 50,000 |
| ជីប្រភេទលេខ ៤-៣-៣ សារធាតុសរីរាង្គ ៦៥% | គីឡូ | 6 | 3,000 | 18,000 | | 18,000 |
| ថ្នាំសម្លាប់សត្វល្អិត ជំងឺ | ឈុត | 1 | 10,000 | 10,000 | | 10,000 |
| ថ្លៃកម្មករដាំ និងថែទាំ | នាក់ | 7 | 30,000 | 210,000 | | 210,000 |
| ប្រេងឥន្ធនៈ | លីត្រ | 4 | 4,000 | 16,000 | | 16,000 |
| ២.ខ. ចំណាយមិនប្រែប្រួល/ថេរ (រំលោះ ៨វដ្ត/ឆ្នាំ) | | | | | | **510,000** |
| ផ្ទះសំណាញ់ (៥ឆ្នាំ) | ផ្ទះ | 1 | 14,000,000 | 14,000,000 | 40 | 350,000 |
| ស្ទូឡាបូមទឹក (៥ឆ្នាំ) | គ្រឿង | 1 | 2,000,000 | 2,000,000 | 40 | 50,000 |
| ម៉ាស៊ីនវៃដី (៥ឆ្នាំ) | គ្រឿង | 1 | 2,400,000 | 2,400,000 | 40 | 60,000 |
| ប្រព័ន្ធទឹក (២ឆ្នាំ) | ឈុត | 1 | 400,000 | 400,000 | 16 | 25,000 |
| ធុងបាញ់ថ្នាំ ២០លីត្រ (៣ឆ្នាំ) | ឈុត | 1 | 120,000 | 120,000 | 24 | 5,000 |
| អណ្ដូងបុក(១០ឆ្នាំ) | ឈុត | 1 | 1,400,000 | 1,400,000 | 80 | 17,500 |
| ស្បៃពណ៌ខៀវ(៣ឆ្នាំ) | ដុំ | 1 | 60,000 | 60,000 | 24 | 2,500 |
| **៣-ចំណេញសរុប** | | | | | | **568,000** |
| **ថ្លៃដើម/គ.ក** = ចំណាយសរុប/ទិន្នផល | | | | | | **2,080** |
| **ចំណេញ/គ.ក** = ចំណេញសរុប/ទិន្នផល | | | | | | **1,420** |

## ៦-លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ៖

| ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ-ខាត | |
|---|---|---|---|---|---|
| | | | | រៀល | % |
| 400 | 1,500 | 600,000 | 832,000 | -232,000 | -39% |
| 400 | 2,000 | 800,000 | 832,000 | -32,000 | -4% |
| 400 | 2,500 | 1,000,000 | 832,000 | 168,000 | 17% |
| 400 | 3,000 | 1,200,000 | 832,000 | 368,000 | 31% |
| 400 | 3,500 | 1,400,000 | 832,000 | 568,000 | 41% |
| 400 | 4,000 | 1,600,000 | 832,000 | 768,000 | 48% |

## ៧-ខ្សែច្រវ៉ាក់តម្លៃ៖

**កសិករ**

លក់ឱ្យឈ្មួញកណ្ដាល ៣,៥០០៛/គ.ក

ថ្លៃដើមផលិត ២,០៨០៛/គ.ក

ចំណេញ ១,៤២០៛/គ.ក

**ឈ្មួញកណ្ដាល**

បោះដុំ ៦,០០០៛/គ.ក ថ្លៃដឹកជញ្ជូន

លាងសម្អាត វេចខ្ចប់ ១,០០០៛/គ.ក

ចំណេញ ១,៥០០៛/គ.ក

**អ្នកលក់រាយ**

លក់រាយ៨,០០០៛ ថ្លៃជួលតូប ខូចខាត

ម៉ាស៊ីនត្រជាក់ ១,០០០៛/គ.ក

ចំណេញ ១,០០០៛/គ.ក

**៨-ការដាំដុះលក្ខណៈទីលជុំ** ដើម្បីទទួលបានចំណូល ៦,០០០ដុល្លារ ឬ ២៤,០០០,០០០រៀលក្នុង១ថ្ងៃ (តម្រូវការផ្ទៃដីដាំដុះវិលជុំ)

| ករណីដោយផ្អែកតាមតម្លៃលក់/គ.ក | លទ្ធផលជាក់ស្តែងក្នុង១ហិកតា | | | ផែនការ | | | |
|---|---|---|---|---|---|---|---|
| | ទិន្នផលជាមធ្យម គ.ក/ហ.ត | តម្លៃ ៛/គ.ក | ចំណូលពីការលក់សរុប | ចំណូលពីការលក់ 6000$/ថ្ងៃ 24,000,000៛ | តម្រូវការផ្ទៃដីដាំដុះវដ្ត/ហ.ត | តម្រូវការផ្ទៃដីដាំដុះវិលជុំជាហិកតា | តម្រូវការចំនួនផ្ទះសំណាញ់ |
| A | B | C | D=B*C | E | F=E/D | G=F*35[១] | H=G/0.025 |
| **ករណីទី១** | 10,000 | 1,500 | 15,000,000 | 24,000,000 | 1.6 | 56 | 2,240 |
| **ករណីទី២** | 10,000 | 2,000 | 20,000,000 | 24,000,000 | 1.2 | 42 | 1,680 |
| **ករណីទី៣** | 10,000 | 2,500 | 25,000,000 | 24,000,000 | 0.96 | 33.6 | 1,344 |
| **ករណីទី៤** | 10,000 | 3,000 | 30,000,000 | 24,000,000 | 0.8 | 28 | 1,120 |
| **ករណីទី៥** | 10,000 | 3,500 | 35,000,000 | 24,000,000 | 0.69 | 24 | 960 |
| **ករណីទី៦** | 10,000 | 4,000 | 40,000,000 | 24,000,000 | 0.6 | 21 | 840 |

**សម្គាល់** ÷ ទិន្នផលទទួលបាន ៤០០គ.ក/ផ្ទះសំណាញ់ សាងសង់បាន២៥ផ្ទះសំណាញ់/ហិកតា

35[១] ចំនួនថ្ងៃដាំដុះ២៥ ថ្ងៃ និងរៀបចំដី ១០ថ្ងៃ ក្នុងមួយវដ្ត

**៩-ហានិភ័យ** ÷

តាមរយៈនៃការចុះសិក្សាជាមួយកសិករដាំដំណាំស្ពៃតឿ មានហានិភ័យមួយចំនួនដែលអាចកើតឡើងជាយថាហេតុលើដំណើរការដាំដុះ បង្កឱ្យមានផលវិបាក និងផលប៉ះពាល់ដល់ផលិតកម្ម។ ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ កសិករត្រូវពិនិត្យមើលហានិភ័យចម្បងៗ និងវិធានការដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | **ហានិភ័យផលិតកម្ម** | ទិន្នផលធ្លាក់ចុះ បណ្តាលមកពីកត្តា<br>-សត្វល្អិត និងជំងឺផ្សិត<br>-កំដៅកើនឡើងក្នុងផ្ទះសំណាញ់នៅរដូវប្រាំង | -គួរប្រើប្រាស់អន្ទាក់ពន្លឺសម្រាប់ទាក់មេអំបៅ និងប្រើប្រាស់វិធានការគីមី ដើម្បីកម្ចាត់ដង្កូវស៊ីបណ្តូល និងទាកគូ |

| | | | |
|---|---|---|---|
| | | | -ដំណាំរលួយគល់ និងរលាកចុងស្លឹក ដែលបង្កដោយមេរោគផ្សិត ឬដាក់ជីគីមីច្រើនជ្រុល ត្រូវតាមដានឱ្យបានទៀងទាត់<br>-គួរគ្របស្បៃការពារពន្លឺ ដោយទុកចន្លោះខ្លះសម្រាប់ពន្លឺព្រះអាទិត្យចែងចាំងចូលក្នុងផ្ទះសំណាញ់ |
| ២ | **ហានិភ័យទីផ្សារ** | ពីខែធ្នូ ដល់ មេសា ស្ពៃតឿធ្លាក់តម្លៃ ដោយសារអាកាសធាតុអំណោយផល ដែលអាចដាំដុះនៅទីវាល និងនៅទីផ្សារសំបូរបន្លែ | -គួរដាំដុះដំណាំច្រើនមុខ ដើម្បីការពារការធ្លាក់តម្លៃ<br>-ពង្រីកបណ្តាញទីផ្សារឱ្យបានច្រើន ដើម្បីកាត់បន្ថយការពឹងផ្អែកលើទីផ្សារក្នុងតំបន់តែមួយ<br>-ចងក្រងក្រុមផលិត ដើម្បីធ្វើកិច្ចសន្យាទិញ-លក់ និងធ្វើផែនការផលិតកម្មតាមកិច្ចសន្យា<br>-ផលិតឱ្យបានទាំងបរិមាណ និងគុណភាពបន្លែ<br>-ធ្វើការស្រាវជ្រាវព័ត៌មានទីផ្សារជាប្រចាំ |

## ១០-សេចក្តីសន្និដ្ឋាន

តាមរយៈការចុះជួបកសិករផ្ទាល់បានបង្ហាញថា ស្ពៃតឿគឺជាដំណាំងាយស្រួលថែទាំ អាយុកាលដាំដុះខ្លី មិនសូវមានកត្តាចង្រៃបំផ្លាញ ទីផ្សារមានតម្រូវការជារៀងរាល់ថ្ងៃ។ ជាក់ស្តែងកសិករដាំស្ពៃតឿក្នុងផ្ទះសំណាញ់នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ទិន្នផលទទួលបានជាមធ្យម ៤០០គ.ក/២៥០ម៉ែ$^{២}$ ជាទិន្នផលខ្ពស់មិនទាមទារការថែទាំខ្លាំង ការដាក់ជី និងការប្រើប្រាស់ថ្នាំពុលគីមីច្រើនក្នុងការដាំដុះឡើយ។ កសិករគួរប្រើប្រាស់ជីលាមកសត្វ និងបន្ថែមជីគីមីបន្តិចបន្តួចដើម្បីបំពេញតម្រូវការលូតលាស់។

ដំណាំស្ពៃតឿមិនសូវខ្វះទីផ្សារនោះទេដោយមានឈ្មួញប្រមូលទិញសម្រាប់លក់នៅទីផ្សារធម្មតា និងផ្សារទំនើបផងដែរ។ ការដាំដុះស្ពៃតឿក្នុងផ្ទះសំណាញ់ មានលក្ខណៈងាយស្រួលដល់កសិករដើម្បីផ្គត់ផ្គង់ទៅទីផ្សារទាំងក្នុងរដូវប្រាំង និងវស្សា ថែមទាំងបានកាត់បន្ថយការប្រើប្រាស់ថ្នាំពុលបានមួយចំនួនធំក្នុងការដាំដុះ និងជាផ្នែកមួយក្នុងការបង្កើនគុណភាព សុវត្ថិភាពបន្លែសម្រាប់អ្នកបរិភោគ។

**ប្រភពនៃការសិក្សាស្រាវជ្រាវ÷**

-កសិករដាំដុះស្ពៃតឿក្នុងផ្ទះសំណាញ់ស្ថិតនៅឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

-ឯកសារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ